ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រីអៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺ
## អេដស៍ថ្លែងក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍

## នាថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៣

## នៅសាលសន្និសីទចតុមុខ

«ឆ្ពោះទៅរកភាពគ្មានការឆ្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់»

- សូមគោរពអង្គពិធីទាំងមូល
- សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- សូមគោរពគណអធិបតី ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា និង រដ្ឋសភា
- ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកអគ្គរាជទូត រដ្ឋទូត តំណាងអង្គទូតនានានៅកម្ពុជា
- លោកស្រី Marie-Odile Emond តំណាងអង្គការ UNAIDS ប្រចាំនៅកម្ពុជា ។
- លោក-លោកស្រីតំណាងអង្គការសង្គមស៊ីវិល និង អ្នករស់នៅជាមួយមេរោគអេដស៍
- លោក.លោកស្រីជាភ្ញៀវជាតិ អន្តរជាតិ និង ក្មួយៗសិស្ស និស្សិតទាំងអស់ ជាទីរាប់អាន!

ជាកិច្ចចាប់ផ្តើម ក្នុងឋានៈជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ខ្ញុំមានកិត្តិយសសូមសំដែងនូវកិច្ចស្វាគមន៍ចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នាថ្ងៃទី ០១ធ្នូ ឆ្នាំ២០១៣នេះ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះវត្តមានរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញជាអធិបតីនៅក្នុងទិវាពិភពលោកនេះ ។

នៅក្នុងសេចក្តីផ្តើមនៃសារ សម្រាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ លោក Michel Sidibé នាយកប្រតិបត្តិនៃ UNAIDS និង អនុអគ្គលេខាធិការអង្គការសហប្រជាជាតិ សរសេរថា៖ “នៅពេលយើងជួបជុំគ្នា ដើម្បីរំលឹកវិញ្ញាណក្ខ័ន្ធ មិត្តភក្តិ និង ក្រុមគ្រួសារដែលបានបាត់បង់ជីវិតដោយសារជម្ងឺអេដស៍ យើងក៏អាចរីកកាយសម្លឹងទៅអនាគត ប្រកបដោយក្តីសង្ឃឹមដ៏ធំធេង”។ ខ្ញុំក៏មានជំនឿដូចនេះដែរ ដោយសារអ្វីដែលយើងសម្រេចបាន និង ដោយសារការប្តេជ្ញាចិត្តដ៏រឹងមាំរបស់យើងទាំងអស់គ្នាឆ្ពោះទៅរកជោគជ័យ គឺការកសាងជំនាន់ថ្មីមួយដែលគ្មានមេរោគអេដស៍នៅកម្ពុជា។

ថ្ងៃនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍របស់ព្រះរាជាណាចក្រកម្ពុជាយើងមានមោទនភាពយ៉ាងក្រៃលែង ដែលបានចូលរួមជាមួយពិភពលោកទាំងមូលក្នុងការរៀបចំប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ធ្នូ ឆ្នាំ២០១៣ ។

នៅក្នុងទិវាដ៏វិសេសវិសាលនេះ ខ្ញុំក៏សូមអនុញ្ញាតជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និង បងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រោមការដឹកនាំដ៏ឈ្លៀសវៃ និង ការប្តេជ្ញាចិត្តនយោបាយដ៏មោះមុត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តែងតែចូលរួមជាមួយពិភពលោក ក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ជារៀងរាល់ឆ្នាំ ដែលរៀបចំឡើងជាទៀងទាត់ នៅទូទាំងពិភពលោកនៅថ្ងៃទី០១ធ្នូ ដោយប្រើប្រាស់សាររួមគ្នាមួយ ក្នុងគោលបំណងបង្ហាញពីឆន្ទៈ ក្នុងការចូលរួមជាមួយពិភពលោក ។

ក្រៅពីនេះ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ក៏មានបំណងលើកកម្ពស់ការយល់ដឹងថ្មីៗ ពីការរាលដាលមេរោគអេដស៍ និង ចំណេះដឹងវិទ្យាសាស្ត្រ ប្រកបដោយប្រសិទ្ធភាពជូនដល់សាធារណជនទូទៅ និង ជាការដាស់ស្មារតីប្រជាពលរដ្ឋឲ្យចងចាំជានិច្ចពីគ្រោះថ្នាក់នៃការចម្លងមេរោគអេដស៍ និង ជំងឺអេដស៍ផងដែរ។ លើសពីនេះទៅទៀត ទិវានេះក៏មានបំណងនឹងស្វែងរកការគាំទ្របន្ថែមទៀត ពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋគ្រប់ស្រទាប់ រាល់ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិលទាំងអស់ ក្នុងការចូលរួមវិភាគទាន ដល់ការទប់ស្កាត់ការរាលដាលមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និង នៅលើពិភពលោកទាំងមូលក្រោមពាក្យស្លោក«**ឆ្ពោះទៅរកគោលគ្មានការឆ្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់**» ។

ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវជាតិ អន្តរជាតិជាទីគោរព និងអ្នកៗនិស្សិតសិស្សានុសិស្ស ជាទីរាប់អាន!

ពាក្យស្លោក«**ឆ្ពោះទៅរកគោលគ្មានការឆ្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់**» មាន គោលដៅផ្សព្វផ្សាយនូវសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ រួមជាមួយនឹងមេដឹកនាំនៃរដ្ឋជាសមាជិកទាំងអស់ ដែលបានប្តេជ្ញាចិត្តជានយោបាយ នៅក្នុងកិច្ចប្រជុំកំពូលនៃមហាសន្និបាតវិសាមញ្ញអង្គការសហប្រជាជាតិលើកទី៦៥ កាលពីខែមិថុនា ឆ្នាំ២០១១ នាបូរីញូវយ៉កដើម្បីចូលរួមពង្រឹងការប្រយុទ្ធនឹងជំងឺអេដស៍ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត ឈានទៅរកការកាត់ផ្តាច់ទាំងស្រុង នូវការចម្លងមេរោគអេដស៍នៅលើពិភពលោក នាឆ្នាំ២០២០ ។

លើសពីនេះទៅទៀត ពាក្យស្លោកនេះ ក៏មានគោលបំណង លើកកម្ពស់នូវការចូលរួម និង ការប្តេជ្ញាចិត្តបន្ថែមទៀត ពីថ្នាក់ដឹកនាំនៅគ្រប់កំរិតទាំងអស់ ចាប់ផ្តើមចេញពីការដឹកនាំបុគ្គលផ្ទាល់ខ្លួនម្នាក់ៗ ឈានទៅរកការដឹកនាំគ្រួសារ សង្គម ប្រទេស និង ពិភពលោកទាំងមូលឲ្យចាកផុតពីការគំរាមកំហែងនៃមេរោគអេដស៍ និង ជំងឺអេដស៍ តាមរយៈការកំណត់នូវ"**គោលដៅបីសូន្យ**"**គឺ១)គ្មានការចម្លងមេរោគអេដស៍ថ្មី)២)គ្មានការរើសអើងនៅលើអ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍**និង **៣)គ្មានការស្លាប់ដោយសារជំងឺអេដស៍** នៅត្រឹមឆ្នាំ២០២០ តាមរយៈការអនុវត្តន៍នូវ"**យុទ្ធសាស្ត្របីសូន្យ**"។

ឆ្លៀតក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំក៏សូមការអនុញ្ញាត ពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង អង្គពិធីទាំងមូល បង្ហាញដោយសង្ខេបពីសមិទ្ធិផល និង ជោគជ័យដែលប្រទេសកម្ពុជាទទួលបានលើការងារទប់ស្កាត់ ការរាលដាលមេរោគអេដស៍ នៅកម្ពុជាក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ។

- យោងតាមការព្យាករណ៍តាមបែបវិទ្យាសាស្ត្រ នៅត្រឹមឆ្នាំ២០១៣នេះ អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យ ដែលមានអាយុពី១៥-៤៩ឆ្នាំគឺមាន០.៧% ដែល

បន្តធ្លាក់ចុះពី០.៨%នៅក្នុងឆ្នាំ២០១១ មានន័យថា កម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យ ការរាលដាលមេរោគអេដស៍ ប្រកបដោយជោគជ័យ និងប្រកបដោយក្តីសង្ឃឹមថា នឹងបន្តធ្លាក់ចុះជាបន្តទៀត នៅឆ្នាំខាងមុខ។

- ចំពោះការថែទាំ និង ព្យាបាលវិញ ក៏កម្ពុជាអាចសម្រេចផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានរហូតដល់ទៅ៨៥% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍ ហើយ សង្ឃឹមថា នឹងអាចឈានទៅសំរេចបាន ១០០% នៅក្នុងឆ្នាំ២០១៥ ខាងមុខនេះ ។
- ដោយឡែកមានអ្នកផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ កុមារកំព្រា និង កុមារងាយរងគ្រោះដោយសារជំងឺអេដស៍ ប្រមាណជា៧០% ដែលតែងតែទទួលបាននូវការគាំទ្រសង្គម សេដ្ឋកិច្ច សុខភាព អប់រំ ។ល។ ជាពិសេស គឺតាមរយៈការងារមនុស្សធម៌ដែលមិនចេះនឿយហត់ និងមិនចេះរីងស្ងួតរបស់កាកបាទក្រហមកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាមគ្គុទេសក៍ជំនើមប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ។
- អ្វីដែលជាសមិទ្ធិផលលេចធ្លោសម្រាប់ឆ្នាំនេះ គឺកំណើនអត្រាស្ត្រីមានផ្ទៃពោះដែលបានមកប្រើប្រាស់សេវាកាត់បន្ថយការចម្លងមេរោគអេដស៍ ពីម្តាយទៅកូន និងកំណើនអត្រាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ដែលបានទទួលការព្យាបាល បង្ការការចម្លងមេរោគអេដស៍ទៅកូន ។ ជាលទ្ធផល អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូន គឺមានកំរិតត្រឹមតែ២%ប៉ុណ្ណោះ រួមនឹងក្តីសង្ឃឹមប្រកបដោយការជឿជាក់ថា កម្ពុជានឹងអាចចូលរួមជាមួយពិភពលោក ក្នុងការកាត់បន្ថយទាំងស្រុង នូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅត្រឹមឆ្នាំ២០១៥ខាងមុខនេះ ។

ដូច្នេះ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការប្តេជ្ញាចិត្តដ៏មោះមុត ក្នុងភាពជាថ្នាក់ដឹកនាំកំពូល ប្រកបដោយគតិបណ្ឌិត និង បញ្ញាញាណដ៏ឧត្តុង្គឧត្តមរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រជានយោបាយ ជាយុទ្ធសាស្ត្រ ជាគោលនយោបាយ ជាពិសេស គោលនយោបាយប្រើប្រាស់ស្រោមអនាម័យ១០០% នៅតាមគ្រឹះស្ថានកំសាន្តសប្បាយទាំងអស់ជាមនុស្សធម៌ ដល់ជនរងគ្រោះដោយសារជំងឺអេដស៍ និង ជាពិសេស ការបង្កើននូវថវិកាជាតិជារៀងរាល់ឆ្នាំ ដើម្បីឲ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានលទ្ធភាពពង្រឹងស្ថាប័នឆ្លើយតបរបស់យើងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណផងដែរ ជូនចំពោះសមាជិកសមាជិការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ជាន់ថ្នាក់ អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ទ្វេភាគី និង ពហុភាគី មូលនិធិសកល អង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ បណ្តាញក្រុមប្រឈមមុខខ្ពស់ នឹងការចម្លងមេរោគអេដស៍ ។ល។ ដែលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការសំរេចបាននូវសមិទ្ធិផលជាទីមោទនៈសម្រាប់ប្រទេសកម្ពុជានាពេលនេះ ។

មុននឹងបញ្ចប់ ខ្ញុំសូមការអនុញ្ញាតពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង អង្គពិធីទាំងមូល ផ្តល់នូវសារមួយចំនួនជូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៖

១.សូមប្រជាពលរដ្ឋទាំងអស់ មេត្តាស្វែងយល់ឲ្យបានជាប្រចាំ នូវចំណេះដឹងថ្មីៗ ស្តីពីការបង្ការ ការចម្លងមេរោគអេដស៍ ដើម្បីប្រើប្រាស់ការពារខ្លួនយើង គ្រួសារយើង និងសង្គមជាតិយើង ពីគ្រោះថ្នាក់នៃជំងឺអេដស៍ ។

២.បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអតិថិជនទាំងអស់ ត្រូវប្រកាន់ខ្ជាប់ នូវការប្រើប្រាស់ស្រោមអនាម័យ ឲ្យបាន១០០% ។

៣.បុរសកម្ពុជា ត្រូវចូលរួមយ៉ាងសកម្ម ក្នុងការទទួលខុសត្រូវចំពោះខ្លួនឯងផ្ទាល់ ប្រពន្ធ និងកូនចៅរបស់ខ្លួន ពីការចម្លងមេរោគអេដស៍ ដោយប្រកាន់ខ្ជាប់ នូវការប្រព្រឹត្តប្រកបដោយសុវត្ថិភាពនិងការទទួលខុសត្រូវ ។

៤.ក្មេងៗយុវវ័យទាំងអស់ មិនត្រូវឆាប់ប្រឡូក នឹងការរួមភេទនោះទេ ហើយត្រូវចាកចេញឲ្យឆ្ងាយ ពីការប្រើប្រាស់គ្រឿងញៀន ដែលជាប្រភពគ្រោះថ្នាក់ខ្ពស់ នៃការចម្លងមេរោគអេដស៍ ។

៥.ស្ត្រីមានផ្ទៃពោះទាំងអស់ជាមួយស្វាមី ត្រូវស្វែងរកសេវាបង្ការ ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ឲ្យបានទាន់ពេលវេលា ។

៦.យើងទាំងអស់គ្នា ត្រូវចូលរួមលុបបំបាត់ការរើសអើង និងមាក់ងាយដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ឲ្យបានជាដាច់ខាត ។

៧.អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ទាំងអស់ ត្រូវស្វែងរកការថែទាំ និងព្យាបាលឲ្យបានឆាប់ ព្រមទាំងគោរពវេជ្ជបញ្ជារបស់គ្រូពេទ្យ ឲ្យបានខ្ជាប់ខ្ជួន ដើម្បីចៀសវាងឲ្យបាននូវភាពស៊ាំរបស់មេរោគអេដស៍ ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ ដែលជាមូលហេតុធ្ងន់ធ្ងរនៃមរណភាពដោយសារជំងឺអេដស៍ ។

ខ្ញុំក៏សូមការគាំទ្រពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងដៃគូអភិវឌ្ឍន៍ទាំងអស់ ជាបន្ថែមទៀត ក្នុងការជួយបន្ត និងបង្កើនការគាំទ្រហិរញ្ញវត្ថុ ដើម្បីឲ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានលទ្ធភាពពង្រីកអន្តរាគមន៍គ្របដណ្តប់ទៅលើភូមិសាស្ត្រ ក្រុមគោលដៅ និង

សេវាបានលឿន និង ប្រកបដោយចេរភាព ឈានទៅសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស និង គោលដៅសូន្យបី នាឆ្នាំ២០២០ ខាងមុខនេះ ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះលោកស្រី Marie-Odile Emond តំណាងអង្គការ UNAIDS ប្រចាំនៅកម្ពុជាដែលបានគាំទ្រ និងចូលរួមយ៉ាងសកម្ម ក្នុងការងារអេដស៍កន្លងមក ដែលជាការរួមចំណែកមួយ ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ បានជោគជ័យនៅកម្ពុជា។ ខ្ញុំក៏សង្ឃឹមទុកជាមុនផងដែរថា នៅក្នុងការចូលរួមមតិយោបល់ថ្ងៃនេះ គឺជាការតាំងចិត្ត ក្នុងការរួមចំណែកបន្ត ក៏ដូចជាដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តឲ្យសំរេចគោលដៅសូន្យបីនៅកម្ពុជា ។ ខ្ញុំសូមថ្លែងអំណរគុណ ដល់តំណាងអង្គការសង្គមស៊ីវិល និងអ្នករស់នៅជាមួយមេរោគអេដស៍ ដែលបានចូលរួមសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធ ប្រឆាំងនឹងជំងឺអេដស៍នៅកម្ពុជា និងសូមអំពាវនាវបន្តការសហប្រតិបត្តិការជាបន្តទៀត ។

ចេញពីស្មារតីនៃថ្ងៃប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍យើងម្នាក់ៗត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីសំរេចលទ្ធផលជាក់ស្តែងក្នុងការងារអេដស៍។លទ្ធផលទាំងនោះនឹងបញ្ជាក់នូវគុណតំលៃនៃការងាររួមរបស់យើងទាំងអស់គ្នាដែលសំដែងចេញជាពិសេសនូវការគោរពដល់ភាពថ្លៃថ្នូររបស់បុគ្គលរាល់រូបនៅក្នុងសង្គមជាតិយើង។

យើងជឿជាក់ថាយើងអាចរួមគ្នាសំរេចគោលដៅបីសូន្យ!

យើងជឿជាក់ថាយើងអាចរួមគ្នាកសាងជំនាន់ថ្មីមួយដែលគ្មានមេរោគអេដស៍នៅកម្ពុជា!

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**និងអង្គពិធីទាំងមូល នូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងសូមកោតសរសើរផងដែរ ចំពោះសមាជិក សមាជិកាទាំងអស់ នៃគណៈកម្មការរៀបចំអង្គពិធី និង ម្ចាស់មូលនិធិទាំងអស់ ដែលបានរួមចំណែកដល់ការរៀបចំពិធីនេះ ប្រកបដោយជោគជ័យ ។

*សូមអរគុណ*